

# THE INTERNATIONAL DAY FOR BIOLOGICAL DIVERSITY

## Peam Krasob Wildlife Sanctuary

## Koh Kong Province

**22 May 2014**

## Table of Contents

**Introduction** .......... **1**
**Objective of the International Day for Biological Diversity** .......... **1**
**The International Day for Biological Diversity Components** .......... **1**
**Session 1: Opening "The International Day for Biological Diversity 2014 (IDB-2014)"** .......... **2**
1.1 Welcome Remark .......... 2
1.2 - Speech on the Important of Biodiversity and the background of the IDB celebrativon .......... 2
1.3 Reminiscence .......... 3
**Session 2: Symbolic Mangrove Plantation** .......... **4**
Annex: .......... **Error! Bookmark not defined.**
Annex1: The International Day for Biological Diversity .......... 5
Annex2: Lists of Participants .......... 6
Annex3: Welcome remark by H.E Bun Leuk, Koh Kong Provincial Governor .......... 10
Annex4: Speech by H.E. Chay Samith .......... 11
Annex 5: Reminiscence by H.E Say Samal, Minister of Environment and Chair of Biodiversity Steering Committee .......... 13
Annex6: Photo Album before and during the International Day for Biological Diversity .......... 15
6.1. Banner and Poster Photo .......... 15
6.2. Before arrival of Honorable Guests .......... 16
6.3. The International Day for Biological Diversity .......... 17

## Introduction

On June 05, 1992 state and government leaders agreed on a strategy for sustainable development at the United Nations Conference on Environment and Development, also known as "The Earth Summit", in Rio de Janeiro, Brazil and the United Nations Convention on Biological Diversity (UN-CBD) came into force on December 29, 1993. The UN-CBD consists of three objectives including the conservation of biological diversity, the sustainable use of its components, and the fair and equitable sharing of benefits arising from the use of genetic resources. Cambodia became a member of UN-CBD on February 09, 1995.

The United Nations General Assembly assigned the 22 of May of each year as the International Day for Biological Diversity - a day to reflect on the state and the importance of biodiversity. A wide range of events are organized globally to increase the understanding of the important role of biodiversity in our future by state members and other organizations. Three of the objectives of the International Day for Biological Diversity are to review the achievements of the convention text of UN-CBD; enhancing understanding of the values of biodiversity resources and the roles of ecosystems for national social economics and strengthening the national international cooperation and incentives to all stakeholders for sustainable biodiversity resources.

## Objective of the International Day for Biological Diversity

The International Day for Biological Diversity falls into the context of Island Biodiversity. Cambodia celebrated the International Day for Biological Diversity on May 22, 2014 with honourable guests: His Excellency **Say Samal**, Minister of Environment and Chair of the Biodiversity Steering Committee, His Excellency **Bun Leuk**, Governor of Koh Kong province, and **H.E. Chay Samith,** Delegate of the Royal Government of Cambodia in Charge of GDANCP/MoE and as a National Focal Point of UN-CBD. The International Day for Biological Diversity was celebrated by many stakeholders with a total of 1000 participants from the Biodiversity Steering Committee members (16), Ministry of Environment and line ministry (68), local and international organizations (8) , relevant Koh Kong provincial departments (168), local authorities (10), tourism police (10), provincial red cross (10), police (10), military police (10), local community (300), teachers and students from secondary and high school (210) and university teachers and students (160). 300 trees have been planted (of 5 species) and the majority of them are mangrove trees.

The objective of the International Day for Biological Diversity in Cambodia is to show the government's will for improving natural resources management; to demonstrate the Ministry of Environment efforts as UN-CBD Focal Point and chair of the Biodiversity Steering Committee; to enhance the understanding of values of biodiversity through biodiversity context to the public, especially local community and students; to increase participation from all stakeholders, including investors and private sector on island biodiversity conservation for sustainable livelihood in Cambodia; and to guide and encourage local community, and local authority at Pream Krasob wildlife sanctuary and Kapik island to continue their traditional uses through the participation of mangrove planting and restoring ecosystem in this island.

## The International Day for Biological Diversity Components

The International Day for Biological Diversity is organized in the following two sessions:

1. Opening “The International Day for Biological Diversity 2014 (IDB-2014)”;
2. Symbolic mangrove plantation and visiting of natural mangrove.

## Session 1: Opening “The International Day for Biological Diversity 2014 (IDB-2014)”

### 1.1 Welcoming Remarks



H.E. Bun Leuk, Koh Kong provincial governor, stated that he was honoured to give the welcoming remarks for the International Day for Biological Diversity, and he also thanked organizers and all stakeholders who financially support the preparations of this important day.

In his speech, he mentioned that many islands, rich with natural resources and beautiful landscape, still exist in Koh Kong province. These areas are Kapik island, Sralaov island, Peam Krasoab wildlife sanctuary, Bubtum Sakor national park, Dong Peng multiple use areas. These protected areas play important roles and provide benefits to local people’s livelihoods, national and international tourist attractions sites and environmental balancing in mangrove forest particularly. In addition, Koh Kong also highly values protected landscape, economy, biodiversity, tourism, culture, and education.

In the end, the governor was confident that all participants would actively participate in biodiversity conservation and in restoring our wonderful natural resources. For more details please refer to the opening Speech in Khmer in Annex 3.

### 1.2 - Speech on the Importance of Biodiversity and background of the IDB celebration



After the welcoming remarks by provincial governor, **H.E. Chay Samith,** Delegate of the Royal Government of Cambodia in Charge of GDANCP/MoE and National Focal Point of the UN-CBD gave a speech on the importance of biodiversity and the roles of environmental services. He added that biodiversity plays very important roles in natural environmental balance and preventing climate change; energy sources, wildlife habitat, daily food and other productions for supporting national social economics. In addition, he also raised some concern related to invasive alien species, which are the main threats to biodiversity in islands and coastal areas. 80% of species on islands (1500

species) are disappearing because of invasive alien species, and according to IUCN red list 40% of island species are threatened and near threatened.

In the end, the government delegation had strong hope that the International Day for Biological Diversity this time provides a good opportunity for all stakeholders to understand the values of biodiversity and natural resources for their daily livelihood improvement and ecosystem services. For more details please refer to his speech in Khmer in Annex 4.

### 1.3 Reminiscence



Following the welcoming remarks and the speech on the importance of biodiversity in Cambodia, His Excellency **Say Samal**, Minister of the Environment and Chair of the Biodiversity Steering Committee, gave some case studies of the daily uses of biodiversity values around us. Bees for example are the most important pollinator within all kinds of forest types. Forests provide shelter, nesting sites, water, larval food plants and floral resources. In the United States, high income is generated from raising bees by local community. He added that Cambodia is very lucky that huge mangrove forests are still present in Koh Kong province providing sea food in Cambodia and Southeast Asia.

The International Day for Biological Diversity 2014 theme is Island Biodiversity, and Easter Island is a good example of biodiversity loss. Easter Island created a thriving culture, and other artefacts. However, heavy human activities led to gradual biodiversity loss and extinction of natural resources, which caused the demise of this island. By the time of the United Kingdom sailors arrived, some 100 years later, they found this island. In addition, concern is rising on the continuing ice melting in the South and the North, with associated sea level increase. As results, some agricultural land in Ho Chi Ming, Vietnam and Preynob, Preah Sihanouk province, Cambodia will be impacted. Recently, around 10,000 ha of agricultural land have been impacted by sea water and climate change project built dam to prevent these losses.

In the end, the Minister of Environment called for all stakeholders to conserve biodiversity because biodiversity is our life, and because keeping city and sea clean, this beauty will attract move tourists. For more details please refer to his speech in Khmer in Annex 5.

## Session 2: Symbolic Mangrove Plantation

After the reminiscence by the Minister of Environment, gifts were distributed to students and Red Cross group. Then, the symbolic mangrove plantation started at Peam Krasoap secondary school, Peam Krasoap wildlife sanctuary, Koh Kong province. Finally, the delegation visited the natural mangrove at Peam Krasoap wildlife sanctuary.



## Annex1: The International Day for Biological Diversity

### 22 May 2014 at Peam Krasob Wildlife Sanctuary, Koh Kong Province

| Time | **Description** | **Facilitator/Rapporteur** |
|---|---|---|
| 08:00-08:30 | Arrival of national- international participants and Delegates | Task Force of GDANCP/MoE |
| **Session 1 : Opening "The International Day for Biological Diversity 2014 (IDB-2014)"** | | |
| 08:30- 10:30 | - Agenda Announcement | Ms Ly Sophorn |
| | - National Anthem | All participants |
| | - Welcoming Remarks | **Governor of Koh Kong province** |
| | - Speech on the Important of Biodiversity and the background of the IDB celebration | **H.E. Chay Samith**<br>Delegate of the Royal Government of Cambodia in Charge of GDANCP/MoE and as a National Focal Point of UN-CBD |
| | - Reminiscence | **H.E. Say Samal**<br>Minister of Environment and Chair of the National Biodiversity Steering Committee |
| **Session 2 : Symbolic Mangrove Plantation** | | |
| 10:30-11:30 | - Mangrove plantation | |
| | - Photo session | |
| | - Closing, visiting natural mangrove and Turning back home | |

## Annex 2: Lists of Participants

| ល.រ | គោត្តនាម និងនាម | ចំនួន | តួនាទី |
|---|---|---|---|
| ១ | ឯកឧត្តម សាយ សំអាល់ | ១ | រដ្ឋមន្ត្រី |
| ២ | ឯកឧត្តម ស៊ិន ខ័ណ្ឌី | ១ | អនុរដ្ឋលេខាធិការ |
| ៣ | ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រី | ៦ | ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី |
| ៤ | ឯកឧត្តម លី ស៊ីមអ៊ិម | ១ | អនុរដ្ឋលេខាធិការ នៃក្រសួង អភិវឌ្ឍន៍ជនបទ |
| ៥ | ឯកឧត្តម នុត ច័ន្ទសុខា | ១ | អនុរដ្ឋលេខាធិការ នៃក្រសួង ផែនការ |
| ៦ | ឯកឧត្តម លី ចាណា | ១ | អនុរដ្ឋលេខាធិការ នៃក្រសួង ធនធានទឹក និងឧតុនិយម |
| ៧ | ឯកឧត្តម តុប សុភ័ក | ១ | អនុរដ្ឋលេខាធិការ នៃក្រសួង ទេសចរណ៍ |
| ៨ | ឯកឧត្តម ទុន លាន | ១ | អនុរដ្ឋលេខាធិការ នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល |
| ៩ | ឯកឧត្តម ញ៉ែម សារ៉ន | ១ | អនុរដ្ឋលេខាធិការ នៃក្រសួង សាធារណការ និងដឹកជញ្ជូន |
| ១០ | ឯកឧត្តម តូច សារូ | ១ | អនុរដ្ឋលេខាធិការ នៃក្រសួងអប់រំ យុវជន និងកីឡា |
| ១១ | លោកជំទាវ កុយ សុដានី | ១ | អនុរដ្ឋលេខាធិការ នៃក្រសួង ពាណិជ្ជកម្ម |
| ១២ | ឯកឧត្តម លី ឈួង | ១ | អនុរដ្ឋលេខាធិការ នៃក្រសួង សុខាភិបាល |
| ១៣ | ឯកឧត្តម វង់ សណ្តាប់ | ១ | អនុរដ្ឋលេខាធិការ នៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ១៤ | ឯកឧត្តម តែ ណាវុធ | ១ | អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| ១៥ | ឯកឧត្តម ហេង សុខណាង | ១ | អគ្គលេខាធិការរងគណៈកម្មាធិការ វិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ១៦ | លោក សាយ សុជាតិ | ១ | អភិបាលរង នៃគណៈអភិបាល ខេត្តកោះកុង |
| ១៧ | ឯកឧត្តម គីម ឆៃហៀង | ១ | អភិបាលរង នៃគណៈអភិបាល ខេត្តសៀមរាប |
| ១៨ | ឯកឧត្តម សូ នាក់ | ១ | អភិបាលរង នៃគណៈអភិបាល ខេត្តរតនគីរី |
| ១៩ | លោក គីម ចន្ថាឫទ្ធិ | ១ | |
| ២០ | លោក សូ វាសនា | ១ | |
| ២១ | លោក តូច ច័ន្ទក្រឹស្នា | ១ | |
| ២២ | លោក សួន សំអូន | ១ | |
| ២៣ | លោក អ៊ូ ម៉ានីរ៉ា | ១ | |
| ២៤ | លោក ប៊ូ ច័ន្ទ សិរី | ១ | |
| ២៥ | លោក ជួន វណ្ណា | ១ | |

| | | | |
|---|---|---|---|
| ២៦ | លោក ជា សំអាត | ១ | |
| ២៧ | លោក យូ ចន្ទប្រសិទ្ធ | ១ | |
| ២៨ | ឯកឧត្តម ចាយ សាមិត្ត | ១ | អគ្គនាយក អ.ក.ធ |
| ២៩ | លោកស្រី អ៊ុក សីហា | ១ | អគ្គនាយិការង អ.ក.ធ |
| ៣០ | លោកបណ្ឌិត ទិន ពន្លក | ១ | អគ្គនាយករង អ.ក.ធ |
| ៣១ | លោក គឹម ណុង | ១ | អគ្គនាយករង អ.ក.ធ |
| ៣២ | នាយកដ្ឋានផែនការរដ្ឋបាល ផែនការ គណនេយ្យ និងហិរញ្ញវត្ថុ | ១០ | |
| ៣៣ | នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ | ១០ | |
| ៣៤ | នាយកដ្ឋានឧទ្យានជាតិ | ១ | |
| ៣៥ | នាយកដ្ឋានដែនជម្រកសត្វព្រៃ | ១ | |
| ៣៦ | នាយកដ្ឋានតំបន់ដីសើម និងតំបន់ឆ្នេរ | ១ | |
| ៣៧ | នាយកដ្ឋានប្រែប្រួលអាកាសធាតុ | ១ | |
| ៣៨ | នាយកដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវៈចម្រុះ | ១ | |
| ៣៩ | ឯកឧត្តម ឡុញ ហ៊ាល | ១ | អគ្គនាយកបច្ចេកទេស |
| ៤០ | នាយកដ្ឋានផែនការ និងកិច្ចការច្បាប់ | ១ | |
| ៤១ | នាយកដ្ឋានអប់រំ ផ្សព្វផ្សាយ ព័ត៌មានបរិស្ថាន | ១ | |
| ៤២ | លោកស្រី ចាន់ សុម៉ាលី | ១ | ប្រធាននាយកដ្ឋាន |
| ៤៣ | លោក ម៉េង ម៉ុនីរក្ស | ១ | អនុប្រធាននាយកដ្ឋាន |
| ៤៤ | លោក ជ័យ យុទ្ធារិទ្ធ | ១ | អនុប្រធាននាយកដ្ឋាន |
| ៤៥ | លោក ឯក សេរីសុភាព | ១ | អនុប្រធាននាយកដ្ឋាន |
| ៤៦ | លោក តេ រិទ្ធី | ១ | អនុប្រធាននាយកដ្ឋាន |
| ៤៧ | លោក អ៊ុង សំអឿន | ១ | ប្រធានការិយាល័យ |
| ៤៨ | លោក សេង រដ្ឋធា | ១ | ប្រធានការិយាល័យ |
| ៤៩ | លោកស្រី កែន បូព្រាង | ១ | ប្រធានការិយាល័យ |
| ៥០ | លោក ចក់ សុខវិជ្ជាបុត្រ | ១ | ប្រធានការិយាល័យ |
| ៥១ | លោក ប៊ុច ប៊ុណ្ណាត | ១ | ប្រធានការិយាល័យ |
| ៥២ | លោក កួច គន្ធាវរៈ | ១ | ប្រធានការិយាល័យ |

| | | | |
|---|---|---|---|
| ៥៣ | លោក អ៊ូ រតនៈ | ១ | ជំនួយការ និងអនុប្រធានការិយាល័យ |
| ៥៤ | លោក យក់ សុទ្ធារិទ្ធ | ១ | អនុប្រធានការិយាល័យ |
| ៥៥ | លោក ស្វ៉ាត សូថានីន | ១ | អនុប្រធានការិយាល័យ |
| ៥៦ | លោក ឈិន និត | ១ | អនុប្រធានការិយាល័យ |
| ៥៧ | លោកស្រី អ៊ិន ម៉ានី | ១ | អនុប្រធានការិយាល័យ |
| ៥៨ | លោក ខែក ភារម្យ | ១ | មន្ត្រី |
| ៥៩ | លោក គាត ប៊ុនថាន | ១ | មន្ត្រី |
| ៦០ | លោក ចន្នី សុមេត្តា | ១ | មន្ត្រី |
| ៦១ | អង្គការ សត្វព្រៃ និងរុក្ខជាតិអន្តរជាតិ | ១ | FFI |
| ៦២ | អង្គការ IUCN | ១ | IUCN |
| ៦៣ | អង្គការ ម្លប់បៃតង | ១ | Mlup Baitong |
| ៦៤ | អង្គការ ជីវិតបក្សីអន្តរជាតិ | ១ | Bird Life International |
| ៦៥ | អង្គការ អភិរក្សអន្តរជាតិ | ១ | CI |
| ៦៦ | អង្គការសង្គ្រោះសត្វព្រៃ | ១ | Save Cambodia’s Wildlife |
| ៦៧ | អង្គការសម្ព័ន្ធមិត្តសត្វព្រៃ | ១ | Wildlife Alliance |
| ៦៨ | អង្គការ NGO Forum | ១ | The NGO Forum on Cambodia |
| ៦៩ | អង្គការ អប់រំស្តីពីការរស់នៅជាមួយបរិស្ថាន | ១ | Live & Learn Environment Education |
| ៧០ | ឯកឧត្តម អភិបាល ខេត្តកោះកុង | ១ | |
| ៧១ | មន្ទីរបរិស្ថាន | ១០ | |
| ៧២ | មន្ត្រីឧទ្យានុរក្ស | ១៧ | |
| ៧៣ | មន្ទីរដែនដី នគរូបនីយកម្ម និងសំណង់ | ១០ | |
| ៧៤ | មន្ទីរអភិវឌ្ឍន៍ជនបទ | ១០ | |
| ៧៥ | មន្ទីរធនធានទឹក និងឧត្តុនិយម | ១០ | |
| ៧៦ | មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល | ១០ | |
| ៧៧ | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០ | |
| ៧៨ | មន្ទីរពាណិជ្ជកម្ម | ១០ | |
| ៧៩ | មន្ទីរសុខាភិបាល | ១០ | |
| ៨០ | មន្ទីរកិច្ចការនារី | ១០ | |
| ៨១ | មន្ទីរអប់រំ យុវជន និងកីឡា | ១០ | |
| ៨២ | មន្ទីរផែនការ | ១០ | |
| ៨៣ | មន្ទីរកសិកម្ម | ១០ | |
| ៨៤ | មន្ទីរទេសចរណ៍ | ១០ | |

| | | | |
|---|---|---|---|
| ៨៥ | មន្ទីរព័ត៌មាន | ១០ | |
| ៨៦ | មន្ទីរការងារ | ១០ | |
| ៨៧ | មន្ទីរទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច | ១០ | |
| ៨៨ | មន្ទីរសាធារណៈការ និងដឹកជញ្ជូន | ១០ | |
| ៨៩ | អាជ្ញាធរដែនដី | ១០ | |
| ៩០ | ប៉ូលីសទេសចរណ៍ | ១០ | |
| ៩១ | កាកបាទក្រហមខេត្ត | ១០ | |
| ៩២ | ក្រុមកាយរឹទ្ធ | ១០ | |
| ៩៣ | ស្នងការនគបាលខេត្ត | ១០ | |
| ៩៤ | កងរាជអាវុធហត្ថខេត្ត | ១០ | |
| ៩៥ | ប្រជាពលរដ្ឋ / ប្រជាសហគមន៍ | ៣០០ | |
| ៩៦ | លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស អនុវិទ្យាល័យ និងវិទ្យាល័យ | ២០០ | |
| ៩៧ | សាស្ត្រាចារ្យ និងនិសិត្សមហាវិទ្យាល័យ | ១៦០ | |
| **សរុប** | | **១០០០** | |

## Annex 3: Welcoming remarks by H.E Bun Leuk, Koh Kong Provincial Governor

នាថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នៅដែនជម្រកសត្វព្រៃពាមក្រសោប ខេត្តកោះកុង

-សូមគោរពឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះជាទីគោរព!

-សូមគោរពឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នៃក្រសួងបរិស្ថានជាទីគោរព!

-សូមគោរពឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នៃបណ្តាក្រសួងពាក់ព័ន្ធដែលជាអនុប្រធាន និងជាសមាជិកនៃគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះជាទីគោរព!

-សូមស្វាគមន៍ អស់លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ-អន្តរជាតិ លោកគ្រូ អ្នកគ្រូ និស្សិត និងក្មួយៗសិស្សានុសិស្សទាំងអស់ជាទីរាប់អាន!

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយឥតឧបមា ដែលបានចូលរួមជាគណៈអធិបតីក្នុងទិវាជីវៈចម្រុះអន្តរជាតិឆ្នាំ២០១៤ នេះនៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោប ខេត្តកោះកុង។ជាមួយគ្នានេះដែរ ខ្ញុំពិតជាមានមោទនៈភាពយ៉ាងក្រៃលែងដែលក្រសួងបរិស្ថានបានជ្រើសរើសខេត្តកោះកុង ជាទីកន្លែងសម្រាប់ប្រារព្ធទិវាដ៏មានសារប្រយោជន៍នេះដែលបានផ្តល់ជា ឱកាសក្នុងការផ្សព្វផ្សាយ ដល់មន្ត្រីរាជការ និស្សិត សិស្សានុសិស្ស និងសាធារណៈជនទាំងអស់ ពីតម្លៃនៃធនធានជីវៈចម្រុះ និងផលប្រយោជន៍នានារបស់វាសម្រាប់ជីវិតនៅលើភពផែនដី។ ក្នុងឱកាសដ៏អធិកអធមនេះ តាងនាមឲ្យអាជ្ញាធរខេត្តកោះកុង ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ-អន្តរជាតិ លោកគ្រូ អ្នកគ្រូ និស្សិត និងសិស្សានុសិស្សទាំងអស់ ដែលតំណាងឲ្យស្ថាប័នថ្នាក់ជាតិ មន្ទីរខេត្តពាក់ព័ន្ធ អាជ្ញាធរ និងសហគមន៍មូលដ្ឋាន និងតំណាងអង្គការដៃគូជាតិ និងអន្តរជាតិ ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងទិវាដ៏មានសារៈសំខាន់នាថ្ងៃនេះ។

អង្គពិធីទាំងមូលជាទីគោរព!

ខ្ញុំសូមអនុញ្ញាតជម្រាបជូនថា ខេត្តកោះកុង ជាខេត្តមួយដែលសម្បូរទៅដោយដីកោះ និងធនធានធម្មជាតិដ៏ស្រស់បំព្រងដែលរួមមានដូចជា កោះកាពិ កោះស្រឡៅ ដែនជម្រកសត្វព្រៃពាមក្រសោប ឧទ្យានជាតិបុទុមសាគរ តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែងព្រមទាំងធនធានជីវៈចម្រុះដ៏សម្បូរបែប។តំបន់ការពារធម្មជាតិទាំងនេះបានផ្តល់នូវសារប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់ការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន ការទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ជាពិសេសធនធានធម្មជាតិទាំងនេះបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាលំនឹងបរិស្ថានធម្មជាតិក្នុងតំបន់ជាពិសេសធនធានព្រៃកោងកាង។

ក្នុងចំណោមខេត្តតំបន់ឆ្នេរទាំង៤ ដែលមានព្រៃកោងកាងសរុប ៧៨.៤០៥ ហិចតានោះ ខេត្តកោះកុង គឺជាខេត្តដែលមានព្រៃកោងកាងធំជាងគេបង្អស់ ដែលមានរហូតដល់ ៦២.០០០ ហិចតា ដែលភាគច្រើនគឺស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃពាមក្រសោប។

ដូចនេះហើយ យើងត្រូវទទួលស្គាល់ថា តំបន់ដែនជម្រកសត្វព្រៃពាមក្រសោប ខេត្តកោះកុងជាតំបន់មួយដែលមានអត្ថប្រយោជន៍ និងតម្លៃដ៏ធំធេងដែលមិនអាចកាត់ថ្លៃបាន មានដូចជាតម្លៃជាតំបន់ទីជម្រាល តម្លៃផ្នែកសេដ្ឋកិច្ច តម្លៃជីវសាស្ត្រ តម្លៃផ្នែកសោភណ្ឌភាព និងទេសចរណ៍ តម្លៃផ្នែកវប្បធម៌ តម្លៃផ្នែកអប់រំ និងតម្លៃផ្តល់ការងារ ដែលតម្លៃទាំងអស់នេះ បាននិងកំពុងចូលរួមចំណែកដោយផ្ទាល់ និងដោយប្រយោល ដល់ការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងមូលដ្ឋានរួមមានការហូតផលនេសាទប្រកបដោយនិរន្តរភាព ការប្រមូលអនុផលនានាពីតំបន់ព្រៃកោងកាង ការការពារសហគមន៍ពីហានិភ័យការប្រែប្រួលអាកាសធាតុ និងផ្តល់អត្ថប្រយោជន៍ខាងសេវាកម្មទេសចរណ៍ ព្រមទាំងសេវាកម្មផ្សេងៗជាច្រើនទៀត។

អង្គពិធីទាំងមូលជាទីគោរព និងជាទីរាប់អាន!

ការការពារ និងថែរក្សាធនធានជីវៈចម្រុះពិតជាមានសារៈប្រយោជន៍ណាស់ សម្រាប់ជីវិតនៅលើភពផែនដីនេះ ដូច្នេះការប្រារព្ធទិវាជីវៈចម្រុះអន្តរជាតិនាថ្ងៃនេះគឺជាឱកាសដ៏វិសេសវិសាលសម្រាប់ខេត្តកោះកុងក្នុងការទទួលបាននូវអនុសាសន៍ល្អៗ ពីក្រសួងបរិស្ថានដែលជាពន្លឺបង្ហាញផ្លូវសម្រាប់ខេត្តរៀបចំផែនការគ្រប់គ្រងធនធានទាំងនេះឲ្យកាន់តែមានប្រសិទ្ធិភាពដើម្បីបន្តធានាឲ្យបាននូវការផ្តល់នូវសេវាកម្មនានាពីធនធានជីវៈចម្រុះទាំងនោះ។

ជាថ្មីម្តងទៀត តាងនាមឲ្យអាជ្ញាធរខេត្ត ខ្ញុំសូមសំដែងនូវក្តីសោមនស្សរីករាយ និងថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងារនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថានដែលបានខិតខំរៀបចំនូវទិវាដ៏មានសារៈសំខាន់នេះឡើង នៅលើទឹកដីខេត្តកោះកុង ក្រោមការឧបត្ថម្ភគាំទ្រពីសំណាក់អង្គការដៃគូជាច្រើនដែលឆ្លុះបញ្ចាំងពីកិច្ចសហការដ៏ល្អរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិល។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសំណូមពរ និងសង្ឃឹមថា អង្គការដៃគូនានានឹងបន្តកិច្ចសហការឧបត្ថម្ភគាំទ្រឲ្យកាន់តែជិតស្និទ្ធជាមួយថ្នាក់ខេត្តក្នុងការគ្រប់គ្រងធនធានជីវៈចម្រុះឲ្យកាន់តែប្រសើរឡើង និងសង្ឃឹមថាក្រសួងបរិស្ថាននឹងប្រារព្ធទិវានេះនៅក្នុងខេត្តកោះកុងជារៀងរាល់ឆ្នាំ។

មុននឹងបញ្ចប់ ខ្ញុំសូមជូនពរឲ្យទិវាជីវៈចម្រុះអន្តរជាតិឆ្នាំ២០១៤នាថ្ងៃនេះ ប្រារព្ធទៅដោយរលូនប្រកបដោយភាពជោគជ័យជាស្ថាពរ និងទទួលបានផ្លែផ្កា។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ–អន្តរជាតិ លោកគ្រូ អ្នកគ្រូ និស្សិត និងសិស្សានុសិស្សទាំងអស់ ជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**

## Annex 4: Speech by H.E. Chay Samith

ក្នុងឱកាសប្រារព្ធ “ទិវាជីវៈចម្រុះអន្តរជាតិ ប្រចាំឆ្នាំ២០១៤”

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នៅដែនជម្រកសត្វព្រៃពាមក្រសោប ខេត្តកោះកុង

3

- សូមគោរព ឯកឧត្តម បណ្ឌិត សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាទីគោរព !
- សូមគោរព ឯកឧត្តម ប៊ុន លើត អភិបាលនៃគណៈអភិបាលខេត្តកោះកុង ជាទីគោរព!
- សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រីភ្ញៀវជាតិ និងអន្តរជាតិ លោកគ្រូ អ្នកគ្រូ និងក្មួយៗសិស្សានុសិស្សទាំងអស់ ជាទីមេត្រី!

ក្នុងឱកាសដ៏វិសេសវិសាលនេះ តាំងនាមឱ្យអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន និងរូបខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយសសូមសំដែងនូវក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានចូលរួមក្នុងឱកាសប្រារព្ធ “ទិវាជីវៈចម្រុះអន្តរជាតិ ប្រចាំឆ្នាំ២០១៤ ក្រោមប្រធានបទ ជីវៈចម្រុះតំបន់កោះ” នាពេលនេះ។ ជំនួសមុខឱ្យថ្នាក់ដឹកនាំក្រសួងបរិស្ថាន ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ អង្គការដៃគូជាតិ និងអន្តរជាតិទាំងអស់ ដែលបានផ្តល់កិច្ចសហការឧបត្ថម្ភគាំទ្រដល់ក្រសួងបរិស្ថាន ជាពិសេសជាមួយនាយកដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវៈចម្រុះ ក្នុងការរៀបចំប្រារព្ធទិវានាថ្ងៃនេះឡើង។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ–អន្តរជាតិ លោកគ្រូ អ្នកគ្រូ និងក្មួយសិស្សានុសិស្សទាំងអស់ជាទីគោរព និងជាទីមេត្រី!

ដោយយល់ឃើញពីតម្លៃដ៏ធំធេងនៃធនធានជីវៈចម្រុះ បាននឹងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយធានានូវលំនឹងរបស់បរិស្ថានធម្មជាតិ ទប់ស្កាត់ការប្រែប្រួលអាកាសធាតុ ផ្តល់ប្រភពថាមពល ទីជម្រក ម្ហូបអាហារប្រចាំថ្ងៃ និងផលិតកម្មផ្សេងៗ សម្រាប់ជួយទ្រទ្រង់សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចសហគមន៍មូលដ្ឋាន ព្រមទាំងផ្តល់តម្លៃផ្នែកសង្គម វប្បធម៌ និងសារៈប្រយោជន៍ផ្សេងៗទៀតយ៉ាងច្រើនឥតគណនា ទើបអង្គការសហប្រជាជាតិ បានប្រកាសជាផ្លូវការជ្រើសរើសយកថ្ងៃទី២២ ខែឧសភា សម្រាប់ប្រារព្ធទិវាជីវៈចម្រុះអន្តរជាតិ ជារៀងរាល់ឆ្នាំ ក្នុងគោលបំណងដើម្បីបង្កើនចំណេះដឹង និងស្វែងយល់ឱ្យកាន់តែច្បាស់នូវតម្លៃជីវៈចម្រុះ ក៏ដូចជាបញ្ហាប្រឈមនានាក្នុងការអភិរក្សជីវៈចម្រុះ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ នៅក្នុងឆ្នាំ២០១៤នេះ លេខាធិការដ្ឋានអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ (UN-CBD) បានប្រកាសយកប្រធានបទក្រោមចំណងជើងថា “ជីវៈចម្រុះនៅតំបន់កោះ” សម្រាប់ការប្រារព្ធទិវាជីវៈចម្រុះអន្តរជាតិក្នុងឆ្នាំនេះ ហើយរហូតមកដល់បច្ចុប្បន្ននេះមានប្រទេសចំនួន ៣៥ ប្រទេសហើយ រួមទាំងប្រទេសកម្ពុជាយើងផងដែរ បានចូលរួមអបអរសាទររៀបចំទិវាជីវៈចម្រុះអន្តរជាតិក្នុងឆ្នាំនេះ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ–អន្តរជាតិ លោកគ្រូ អ្នកគ្រូ និងក្មួយៗ សិស្សានុសិស្សទាំងអស់ជាទីគោរព និងជាទីមេត្រី!

ជាភ័ព្វសំណាងដែលរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិត របស់សម្តេចអគ្គ មហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងដល់ការ អភិរក្សធនធានជីវៈចម្រុះ និងបានគាំទ្រដល់ក្រសួងបរិស្ថានក្នុងការអនុវត្តភារៈកិច្ចរបស់ខ្លួនក្នុងនាមជាស្ថាប័នបង្គោលអនុវត្តអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះទាំងនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងសកល។ អាស្រ័យហេតុនេះហើយ ទើបក្រសួងបរិស្ថានមានឱកាសបានសហការជាមួយអាជ្ញាធរដែនដី និងដៃគូជាតិ អន្តរជាតិ ដើម្បីរៀបចំទិវាជីវៈចម្រុះ អន្តរជាតិនាថ្ងៃនេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដែល បានឆ្លៀតពេលវេលាដ៏មានតម្លៃរបស់ឯកឧត្តមផ្តល់កិត្តិយសចូលរួមក្នុងទិវានាពេលនេះ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ–អន្តរជាតិ លោកគ្រូ អ្នកគ្រូ និងក្មួយៗ សិស្សានុសិស្សទាំងអស់ជាទីគោរព និងជាទីមេត្រី!

គោលបំណងនៃការរៀបចំអបអរសាទរទិវាជីវៈចម្រុះអន្តរជាតិ ក្រោមប្រធានបទជីវៈចម្រុះនៅតំបន់កោះ នាថ្ងៃនេះមិនត្រឹមតែបង្ហាញនូវគោលនយោបាយដ៏ឈ្លាសវៃរបស់រាជរដ្ឋាភិបាល និងឆន្ទៈដ៏មោះមុតរបស់ក្រសួងបរិស្ថាន ក្នុង ការអនុវត្តគោលនយោបាយអន្តរជាតិប៉ុណ្ណោះទេ ថែមទាំងបង្កើននូវចំណេះដឹងដល់ប្រជាជនកម្ពុជាទូទាំងប្រទេស ឱ្យស្វែងយល់ពីសក្តានុពលដ៏ធំធេង នៃជីវៈចម្រុះតំបន់កោះ និងសមុទ្រថែមទៀត ព្រោះថាតំបន់កោះគឺជាជម្រករបស់មនុស្សប្រហែលជា៦០០លាននាក់ គឺស្មើនឹង១ភាគ១០ នៃចំនួនប្រជាជនទូទាំងពិភពលោក។ ពិសេសជាងនេះទៀតប្រជាជនរស់នៅតំបន់កោះជាច្រើនមានវប្បធម៌ពិសេសដែលមានតែមួយគត់ និងមានសុខមាលភាពផ្នែកបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលភាគច្រើនត្រូវបានទាញយកដោយផ្ទាល់ ឬដោយប្រយោលពីធនធានធម្មជាតិដ៏សម្បូរបែបនៃប្រព័ន្ធអេកូឡូស៊ីបរិស្ថានរបស់ពួកគេ។ មិនតែប៉ុណ្ណោះ តំបន់កោះ និងសមុទ្រមានប្រភេទអេកូឡូស៊ីផ្សេងៗដាច់ដោយឡែកពីគ្នាជាច្រើន គិតចាប់ពីព្រៃឈើ តំបន់ភ្នំ រហូតដល់តំបន់ទំនាបដីសើម ដែលបានផ្តល់ជាចំណីអាហារ ប្រភពទឹក ឈើ ឱសថ ឥន្ធនៈ ឧបករណ៍ផ្សេងៗ និងវត្ថុធាតុដើមសំខាន់ៗជាច្រើនទៀត បន្ថែមពីលើតម្លៃផ្នែកសោភណ្ឌភាព ការអប់រំ និងការកំសាន្ត សម្រាប់ជួយផ្គត់ផ្គង់ជីវភាព សេដ្ឋកិច្ច និងវប្បធម៌របស់ប្រជាជននៅលើតំបន់ទាំងនោះ។ ក្រៅពីនេះ អេកូឡូស៊ីតំបន់កោះ និងសមុទ្រ ក៏បានរួមចំណែកផងដែរក្នុងការថែរក្សាមុខងារសំខាន់ៗរបស់ប្រព័ន្ធអេកូឡូស៊ីដូចជា៖ រារាំងគ្រោះធម្មជាតិ ជួយក្នុងដំណើរការនៃវដ្តបង្កើតដីមានជីវជាតិ និងខ្សាច់ ព្រមទាំងបានរួមចំណែកក្នុងការរក្សាលំនឹងបរិយាកាស កាត់បន្ថយការប្រែប្រួលអាកាសធាតុ និងទប់ស្កាត់ការរាតត្បាតនៃជំងឺផ្សេងៗ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ–អន្តរជាតិ លោកគ្រូ អ្នកគ្រូ និងក្មួយៗ សិស្សានុសិស្សទាំងអស់ជាទីគោរព និងជាទីមេត្រី!

ធនធានជីវៈចម្រុះត្រូវបានកត់សំគាល់ដូចៗគ្នាក្នុងបរិបទនានាថា សមាសភាព និងសេវាកម្មរបស់វាបានផ្តល់នូវសារប្រយោជន៍យ៉ាងសំខាន់បំផុតសម្រាប់ទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ីតំបន់កោះ។ ក៏ប៉ុន្តែសេដ្ឋកិច្ចនៅតំបន់កោះ ជាពិសេសនៅតាមបណ្តាប្រទេសកោះតូចៗកំពុងអភិវឌ្ឍន៍ជាច្រើន ងាយរងគ្រោះថ្នាក់បំផុតដោយសារតែកង្វះជម្រើសសេដ្ឋកិច្ចដែលបណ្តាលមកពីកត្តានានាជាច្រើនរួមមាន៖ ចំនួនប្រជាជនតិច សេដ្ឋកិច្ចទន់ខ្សោយ និងសមត្ថភាពស្ថាប័នទាំងផ្នែករដ្ឋ និងឯកជននៅមានកំរិត។ ភាពដាច់ស្រយ៉ាលពីទីផ្សារអន្តរជាតិ ភាពងាយទទួលផលប៉ះពាល់ពីគ្រោះធម្មជាតិ និងការប្រែប្រួលអាកាសធាតុ ភាពផុយស្រួយនៃប្រព័ន្ធអេកូឡូស៊ីដីគោក និងសមុទ្រ ក៏ជាកត្តាដែលធ្វើឱ្យប្រជុំកោះតូចៗទាំងនោះងាយទទួល រងគ្រោះជាងគេផងដែរ។ លើសពីនេះទៅទៀត តម្លៃនៃការដឹកជញ្ជូនខ្ពស់ ភាពសំបូរបែបនៃផលិតកម្មនិងការនាំចេញនៅមានកំរិត ភាពពឹងផ្អែកទៅលើទីផ្សារអន្តរជាតិ ការនាំចេញ និងភាពមិនទៀងទាត់នៃប្រាក់ចំណូល និងភាពងាយរងគ្រោះដោយសារការប្រែប្រួលសេដ្ឋកិច្ចពីបរទេស ក៏ជាកត្តាជំរុញឲ្យតំបន់កោះជួបប្រទះនូវឧបសគ្គក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចផងដែរ។

ក្រៅពីនេះ ការរាតត្បាតនៃប្រភេទទន្រ្ទានក្រៅស្រុក (Invasive Alien Species) ក៏បានបង្កនូវការគំរាមកំហែងយ៉ាងខ្លាំងដល់ជីវៈចម្រុះតំបន់កោះ និងសមុទ្រផងដែរ។ តាមការសិក្សាស្រាវជ្រាវ បានបង្ហាញឱ្យឃើញថាប្រហែលជា៨០% នៃប្រភេទដែលបានផុតពូជស្មើនឹង ១៥០០ប្រភេទ គឺជាជីវៈចម្រុះនៅតំបន់កោះ ហើយកត្តាដែលគំរាមកំហែងធំបំផុត និងដោយផ្ទាល់នៃការផុតពូជនោះគឺបណ្តាលមកពីប្រភេទទន្រ្ទានក្រៅស្រុក។ តាមការចុះបញ្ជីប្រភេទដែលបានរងគ្រោះថ្នាក់ និងកំពុងរងគ្រោះថ្នាក់បំផុតនៅក្នុងបញ្ជី IUCN នោះគឺមានយ៉ាងតិច៤០% ស្ថិតនៅក្នុងទីជម្រកនៃតំបន់កោះ។ ដូច្នេះ ប្រភេទទន្រ្ទានក្រៅស្រុកគឺជាហានិភ័យដ៏ធំនៃការគំរាមកំហែងដល់ជីវៈចម្រុះតំបន់កោះ និងសមុទ្រក្នុងពេលបច្ចុប្បន្ននេះ។

ហេតុដូច្នេះហើយ បានជាពិធីអបអរសាទរ ទិវាជីវៈចម្រុះអន្តរជាតិក្នុងឆ្នាំ២០១៤ ក្រោមប្រធានបទ ជីវៈចម្រុះតំបន់កោះ ក្រសួងបរិស្ថានបានជ្រើសរើសយកទីតាំងនៅតំបន់ដែនជម្រកសត្វព្រៃពាមក្រសាបជាកន្លែងប្រារព្ធទិវា និងអមដោយសកម្មភាពដាំកូនឈើ កូនកោងកាង នៅតំបន់កោះកាពិ ដើម្បីស្តារប្រព័ន្ធអេកូឡូស៊ីនៅតំបន់ទាំងនោះសម្រាប់ជាជម្រករបស់ប្រភេទដ៏សំបូរបែបនៃធនធានធម្មជាតិកោះនិងសមុទ្រ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយស លោកគ្រូ អ្នកគ្រូ និងក្មួយៗសិស្សានុសិស្សទាំងអស់ជាទីគោរព និងជាទីមេត្រី!

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ទិវាជីវៈចម្រុះអន្តរជាតិ នាថ្ងៃនេះគឺជាឱកាសដ៏ល្អប្រសើរសម្រាប់ឲ្យយើងទាំងអស់គ្នាស្វែងយល់ពីតម្លៃធនធានធម្មជាតិដែលបានផ្តល់ឲ្យយើងសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ និងសម្រាប់ជួយដល់ការទប់ស្កាត់ការប្រែប្រួលអាកាសធាតុដែលពិភពលោកកំពុងយកចិត្តទុកដាក់ និងព្រួយបារម្ភយ៉ាងខ្លាំង ជាពិសេសគឺការកើន ឡើងនៃកំរិតទឹកសមុទ្រដែលអាចនឹងបង្កឲ្យមានគ្រោះមហន្តរាយដ៏ធំ ឬឈានដល់ការបាត់បង់ទាំងស្រុងនូវកោះមួយ ចំនួន។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរសិរីមង្គលជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិទាំងអស់ សូមជួបប្រទះតែនឹងសេចក្តីសុខ និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមឱ្យ “ទិវាជីវៈចម្រុះអន្តរជាតិ ប្រចាំឆ្នាំ២០១៤ ក្រោមប្រធានបទ ជីវៈចម្រុះតំបន់កោះ” នាពេលនេះប្រព្រឹត្តទៅដោយជោគជ័យ ។

**សូមអរគុណ**

## Annex 5: Reminiscence by H.E Say Samal, Minister of Environment and Chair of Biodiversity Steering Committee

ទិវាជីវៈចម្រុះអន្តរជាតិ ប្រចាំឆ្នាំ២០១៤

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នៅដែនជម្រកសត្វព្រៃពាមក្រសោប ខេត្តកោះកុង

3

- សូមគោរព ឯកឧត្តម ប៊ុន លើត អភិបាលនៃគណៈអភិបាលខេត្តកោះកុង ជាទីគោរព!
- សូមគោរព ឯកឧត្តម លោកជំទាវ ដែលជាសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ
- សូមគោរព ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក អ.ក.ធ
- សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រីភ្ញៀវជាតិ និងអន្តរជាតិ លោកគ្រូ អ្នកគ្រូ និងក្មួយៗសិស្សានុសិស្សទាំងអស់ ជាទីមេត្រី!

យើងបានយល់ពីលិខិតបទដ្ឋានគតិយុទ្ធនានា ដូច្នេះខ្ញុំនឹងលើនូវចំនុចមួយចំនួនហេតុអ្វីបានជាយើងប្រារព្ធទិវាជីវៈចម្រុះនេះឡើងជារាងរាល់ឆ្នាំនៅលើពិភពលោក។ សារៈប្រយោជន៍ដែលជីវៈចម្រុះផ្តល់ឱ្យយើងជារាងរាល់ថ្ងៃនេះមានតម្លៃធំធេញណាស់ ឃ្មុំជាឧទាហរណ៍ស្រាប់ វាមានសារៈសំខាន់ណាស់ក្នុងការផ្តល់នូវសេវាកម្មបរិស្ថានពិសេសនាំយកលំអងផ្កាញី និងឈ្មោលឱ្យជួបគ្នាតាមរយៈការក្រេបលំអងផ្កា។ ឧទាហរណ៍ជាក់ស្តែងមួយការចិញ្ចឹមឃ្មុំនៅសហរដ្ឋអាមេរិចក៏បានផ្តល់ចំណូលជាច្រើនដល់ប្រជាជនផងដែរ។ នៅពេលមួយឃ្មុំកើតជំងឺហើយក៏ងាប់អស់ ហើយទិន្នផលកសិកម្មនៅឆ្នាំនោះក៏ធ្លាក់ចុះ មុនដំបូងមិនដឹកពីមូលហេតុ ប៉ុន្តែអ្នកវិទ្យាសាស្រ្តបានស្រាវជ្រាវស៊ីជម្រៅពីទំនាក់ទំនងរវាងការងាប់របស់ឃ្មុំ និងការថយចុះនៃផលិតកម្មកសិកម្មនៅតំបន់នេះ ជាលទ្ធផលបង្ហាញថាការបាត់បង់វត្តមាននៃសត្វឃ្មុំនេះពិតជាធ្វើឱ្យផលិតផលកសិកម្មចុះទាបមែន។ ទឹកភ្លៀងមានរាល់ថ្ងៃនេះក៏ជាសេវាកម្មបរិស្ថានដែរ យើងមិនអាចបូមទឹកពីទន្លេមកស្រោចស្រពដីកសិកម្មទាំងអស់នោះទេពីព្រោះមានទំហំធំពេក ពិសេសប្រទេសកម្ពុជាជាប្រទេសក្រីក្រតែងតែពឹងលើទឹកភ្លៀងខ្លាំងដែលមានរដូវប្រាំង និងវស្សាដែលនេះជាសេវាកម្មធម្មជាតិដែលយើងអត់មិនបាន។

កម្ពុជាពិតជាមានភ័ពសំណាងណាស់ដែលនៅសេសសល់ព្រៃកោងកាង ពិសេសនៅខេត្តកោះកុងជាខេត្តដែលមានព្រៃកោងកាងច្រើនជាងគេនៅក្នុងចំណោមខេត្តទាំងបួន នៅជាប់មាត់សមុទ្រ ហើយជាកន្លែងដែលផលិតអាហារសមុទ្រនៅកម្ពុជា ក៏ដូចជានៅតំបន់អាស៊ីអាគ្នេយ៍ដែរ ដូច្នេះយើងព្យាយាមការពារព្រៃកោងកាងនេះ។ ជាក់ស្តែងព្រៃកោងកាងភាគច្រើនត្រូវបានគេកាប់ឆ្ការសម្រាប់ចិញ្ចឹមបង្គាចំណែកខេត្តកោះកុងយើងបានថែរក្សាព្រៃកោងកាងបានច្រើន។ ហើយយើងក៏បានដឹងហើយថាប៉ុន្មានឆ្នាំនេះមានស៊ូណាមី នៅប្រទេសឥណ្ឌូនេស៊ី តំបន់បាត់បង់ព្រៃកោងកាងច្រើនជាងគេទទួលរងគ្រោះខ្លាំងជាងគេដោយសារតែព្យុះនេះ។ ទិវាជីវៈចម្រុះអន្តរជាតិ ត្រូវបានកំណត់ជាផ្លូវការយកថ្ងៃទី២២ ខែឧសភាដោយអង្គការសហប្រជាជាតិ ជារៀងរាល់ឆ្នាំដើម្បីប្រារព្ធពិធីដើម្បីអបអរសាទរ និងដឹងគុណដល់សេវាកម្មធម្មជាតិដែលផ្តល់មកឱ្យយើង ដូច្នេះទិវាជីវៈចម្រុះអន្តរជាតិអន្តរជាតិនេះមានគោលបំណងបីដូចខាងក្រោម៖

1. រំលឹកខួបអនុស្សាវរីយ៍នៃការសម្រេចឱ្យប្រើប្រាស់ខ្លឹមសារ (Convention Text) នៃអនុសញ្ញា សហប្រជាជាតិស្តីពី ជីវៈចម្រុះ (UN-CBD)
2. បង្កើនចំណេះដឹងជាសាធារណៈ នៃតម្លៃធនធានជីវៈចម្រុះ និងសារៈប្រយោជន៍នៃសមាសភាព របស់វា រួមទាំងប្រព័ន្ធអេកូឡូស៊ី សម្រាប់សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចសង្គម
3. ពង្រឹងកិច្ចសហប្រតិបត្តិការជាតិ–អន្តរជាតិ និងលើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន ពាក់ព័ន្ធទាំងអស់ ដើម្បីការអភិរក្ស និងការគ្រប់គ្រងធនធានជីវៈចម្រុះប្រកបដោយនិរន្តរភា

សម្រាប់ទិវាជីវៈចម្រុះឆ្នាំនេះ ត្រូវបានប្រារព្ធធ្វើក្រោមប្រធានបទ *"ជីវៈចម្រុះ ដីកោះ"* ។ មានកោះមួយនៅសមុទ្រប៉ាស៊ីហ្វិកឈ្មោះ កោះ Easter មានប្រជាជនច្រើនប្រើប្រាស់ថ្មសម្រាប់សាងសង់ ហើយកោះនេះមានទំនាក់ទំនងទៅនឹងជីវៈចម្រុះ ដោយសារតែការប្រើប្រាស់ធនធានជីវៈចម្រុះច្រើន ធ្វើឱ្យកោះនេះប្រឈមមុខនឹងការខ្វះទឹកសាប និងធនធានធម្មជាតិធ្លាក់ចុះបន្តិចម្តងៗ រហូតដល់កោះនេះបាត់បង់ទៅ។ ប្រហែលជា១០០ឆ្នាំក្រោយអ្នកកប៉ាល់ជនជាតិអង់គ្លេសបានរកឃើញផ្ទះថ្ម និងហេដ្ឋារចនាសម្ព័ន្ធនៅលើកោះនេះ ដូច្នេះការបាត់បង់កោះនេះដោយសារតែ ការប្រើប្រាស់ធនធានជីវៈចម្រុះដោយកម្រោល។ការប្រែប្រួលអាកាសធាតុធ្វើឱ្យភពផែនដីក្តៅ ដែលធ្វើឱ្យទឹកកកនៅប៉ូលខាងត្បូង និងខាងជើងរលាយ ហើយនៅពេលរលាយ មានកោះ៣ទៅ៤មានកិច្ចព្រមព្រាងមយជាមួយប្រទេសអូស្រ្តាលីដើម្បីជម្រៀសប្រជាជននៅពេលកំរិតទឹកសមុទ្រឡើងខ្ពស់។

ដូចគ្នានេះដែរប្រសិនបើទឹកសមុទ្រចេះតែបន្តឡើងតំបន់មួយចំនួននៅប្រទេសវៀតណាមនឹងមិនអាចធ្វើកសិកម្មបានពិសេសតំបន់ហូជីមិញ។ តំបន់កោះកុង និងព្រៃនប់មានការហូរទឹកប្រៃដែល ធ្វើឱ្យប៉ះពាល់ដល់តំណាំស្រូវប្រជាកសិករ ហើយសូមថ្លែងអំណរគុណដល់ក្រុមការងារបំរ៉ែបំរួលអាកាសធាតុដែលធ្វើទំនប់ទប់ទឹកប្រៃអាចជួយការហូរទឹកប្រៃបានប្រមាណ១០០០០ហិចតា ហើយការប្រែប្រួលអាកាសធាតុបានប៉ះពាល់ដល់ជីវៈចម្រុះ។ ដែលអាចជួយអបអរសារទរជីវៈចម្រុះអន្តរជាតិ ប្រជាជនខេត្តកោះកុងក៏គួរតែ អបអរសាទរខ្លួនឯងដែរ កោតសរសើរដល់ឯកឧត្តមអភិបាល គណៈអភិបាល ក្រុមប្រឹក្សាខេត្ត ព្រមទាំងកងរាជអាវុធហត្ថទាំងអស់ បុគ្គលិកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងប្រជាជនខេត្តកោះកុងតែម្តង ខ្ញុំសូមកោតសរសើរ និងអបអរសាទរសហគមន៍

និងមានមោតនភាពដោយយើងបានការពារព្រៃកោងកាងរបស់ខេត្តកោះកុង មិនត្រឹមតែខេត្តកោះកុងប៉ុណ្ណោះទេប៉ុន្តែសម្រាប់ទូទាំងប្រទេសទាំងមូល យើងនឹងបន្តការពារព្រៃកោងកាង។ ទាក់ទងទៅនឹងការអភិរក្សជីវៈចម្រុះនេះក៏ជាគោលនយោបាយថ្មីមួយរបស់រាជរដ្ឋាភិបាល តំបន់ការពារទាំងអស់នៅទូទាំងប្រទេសនឹងត្រូវ (១) កំណត់ព្រំប្រទល់នៅក្នុងអាណត្តិនេះ និងក្រោយ (២) កំណត់ព្រំដែនប្រជារស់នៅ (៣) កំណត់ព្រំប្រទល់ដីសម្បទាន ដើម្បីងាយស្រួលការគ្រប់គ្រងអភិរក្ស ជម្រុញដំសម្បទានធ្វើឱ្យបានលឿន ឧទាហរណ៍នៅភ្នំឱរាល់ចំការអំពៅ អាចរកចំណូលសម្រាប់ប្រជាសហគមន៍ និងដើម្បីឱ្យប្រជាសហគមន៍មានការងារធ្វើ និងមានចូលព្រៃដកហូតផល និងអនុផលព្រៃឈើនៅរដូវប្រាំង។ ដូច្នេះយើងខំកសាងដំណាំកសិឧស្សាហកម្មដើម្បីឱ្យប្រជាសហគមន៍បង្វែរការងារកាប់ឈើងាកមកដំណាំអំពៅវិញ ភ្នំឱរាល់ក៏ជួយរក្សាទឹកសាបដល់ប្រជាជននៅខេត្តកំពង់ស្ពឺផងដែរ។ បង្កើតមូលនិធិអនាម័យបរិស្ថានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិប្រមាណជា៥លានដុល្លាអាមេរិក ដែលមានមុខងារសម្រាប់ឱ្យខេត្តយកទៅសំអាតទីប្រជុំជន រៀបចំកញ្ចប់ថវិការមានមួយចំនួនសម្រាប់ខេត្តកោះកុងពិសេសក្រុងខេមរភូមិន្ទមុនគេសម្រាប់ឱ្យខេត្តរកដៃគូរសម្រាប់សំអាតក្រុងនេះមុនគេ។ លុះត្រាតែយើងរក្សាសម្រស់ និងសោភ័ណ្ឌភាពទីក្រុង និងសមុទ្រទើបមានប្រជាជនតំបន់ផ្សេងៗមកលេង។ អំពាវនាវឱ្យយើងថែរក្សាជីវៈចម្រុះរបស់យើងព្រោះថាជីវៈចម្រុះគឺជាអាយុជីវិតរបស់យើង សូមបីតែខ្យល់ ដី និងទឹក។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរសិរីមង្គលជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិទាំងអស់ សូមជួបប្រទះតែនឹងសេចក្តីសុខ និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសុខភាពល្អ។

**សូមអរគុណ!**

## Annex 6: Photo album before and during the International Day for Biological Diversity

### 6.1. Banner and Poster Photo













## 6.2. Before arrival of Honourable Guests













## 6.3. The International Day for Biological Diversity
















ADB
















ADB
Save Cambodia's Wildlife
UNDP
IUCN



